ក្រុមប្រឹក្សាអាជ្ញាកណ្ដាល
THE ARBITRATION COUNCIL

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ និង ឈ្មោះសំណុំរឿង ៖ ០៣១/១៨ - ខេន ស្កត ស៊ូ**
**កាលបរិច្ឆេទនៃសេចក្ដីបង្គាប់ ៖ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨**

# សេចក្ដីបង្គាប់អាជ្ញាកណ្ដាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្ដីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្ដាល

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **អ៊ឹង សុទ្ធី**

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **លីវ សុវណ្ណា**

ប្រធានក្រុមអាជ្ញាកណ្ដាលជ្រើសរើសឡើងដោយអាជ្ញាកណ្ដាលទាំងពីរខាងលើ ៖ **ប៉ែន ប៊ុនឈា**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ខេន ស្កត ស៊ូ**

អាសយដ្ឋាន ៖ ភូមិចំការស្វាយ ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង

ទូរស័ព្ទ ៖ ០៧៨ ៧៧៧ ៦១៩ ទូរសារ ៖ គ្មាន

តំណាងភាគីនិយោជក ៖

| | |
|---|---|
| ១- លោក សុះ ម៉ើ | រដ្ឋបាល |
| ២- លោក អ៊ុក អ៊ុន | រដ្ឋបាល |
| ៣- លោក ឡាច សារុន | ទីប្រឹក្សាក្រុមហ៊ុន |

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខេន ស្កត ស៊ូ**

អាសយដ្ឋាន ៖ ភូមិចំការស្វាយ ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង

ទូរស័ព្ទ ៖ ០៧៧ ២៣ ០៩ ៧៨ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

| | |
|---|---|
| ១- លោក ហម ស៊ុនរិទ្ធិ | មេធាវីតំណាងដោយអាណត្តិកម្មករនិយោជិត |
| ២- លោកស្រី ម៉ន ចន្ទា | មន្ត្រីសហព័ន្ធសហជីពកម្ពុជា |

| | |
|---|---|
| ៣- កញ្ញា អេង ស្រីទូច | ប្រធានសហជីពកម្ពុជានៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ |
| ៤- លោកស្រី វីន សេរី | អនុប្រធានសហជីពកម្ពុជានៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ |
| ៥- លោកស្រី វ៉ង់ ថារី | ហិរញ្ញិកសហជីពកម្ពុជានៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ |
| ៦- លោក សៀង នីម | អគ្គលេខាធិការសហជីពកម្ពុជានៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ |
| ៧- លោកស្រី ឌឹម រ៉ា | កម្មករ |
| ៨- លោកស្រី គន់ សារ៉ុន | កម្មករ |
| ៩- លោក ថន សុភា | កម្មករ |
| ១០- លោកស្រី ហឹង វ៉ន | កម្មករ |
| ១១- លោកស្រី ចាន់ សារី | កម្មករ |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតនៅតែស្នើឱ្យក្រុមហ៊ុនត្រូវអនុញ្ញាតច្បាប់ជូនកម្មករ (នៅពេលគាត់មានធុរៈ)។

២- កម្មករនិយោជិតនៅតែស្នើឱ្យក្រុមហ៊ុន នៅពេលអត់មានការងារធ្វើ មិនត្រូវឱ្យកម្មករឈប់សម្រាកប្រចាំឆ្នាំឡើយ (ត្រូវគិតជាលុយជូនកម្មករវិញ ពេលសម្រាកកន្លង)។

៣- កម្មករនិយោជិតនៅតែស្នើឱ្យក្រុមហ៊ុនបញ្ឈប់ការរើសអើងចំពោះសហជីពកម្ពុជា។

៤- កម្មករនិយោជិតនៅតែស្នើឱ្យក្រុមហ៊ុនកាត់ភាគទានជូនសហជីពកម្ពុជា ដែលបានដាក់ជូនក្រុមហ៊ុន នាពេលកន្លងមក។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ២២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ (អាណត្តិទី១៦)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ ១១៤១ ក.ប/ក.វ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

THE ARBITRATION COUNCIL

**សវនាការ និង សង្ខេបនីតិវិធី**

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃចន្ទ ១រោច ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក) ។

**បញ្ហានីតិវិធី៖**

នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៨ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង បានទទួលលិខិតស្នើសុំឱ្យជួយដោះស្រាយវិវាទការងាររបស់ភាគីនិយោជក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការទាមទាររបស់កម្មករនិយោជិត ឱ្យក្រុមហ៊ុនកែលម្អរលក្ខខណ្ឌការងារ ចំនួន ៩ ចំណុច។ បន្ទាប់ពីទទួលលិខិតស្នើសុំនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង បានចាត់មន្ត្រីជំនាញឱ្យធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាវិវាទ ចំនួន ៩ ចំណុច ជាលើកចុងក្រោយ នៅថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៨ ដោយទទួលបានលទ្ធផលមិនសះជានឹងគ្នា ចំនួន ៤ ចំណុច លើការទាមទារចំនួន ៩ ចំណុច។ ចំណុចមិនសះជាដែលនៅសល់ទាំង ៤ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ តាមរយៈរបាយការណ៍ ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ ១១៤១ កប/កឆ ចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ២០១៨។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង នៅថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៨។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាទាំង ៤ ចំណុច នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។ ភាគីទាំងពីរ មានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទដែលនៅសល់ទាំងនេះ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជា ចំនួន ៤ ចំណុចនេះ បន្ថែមទៀត ដោយទទួលបានលទ្ធផលសះជានឹងគ្នា ចំនួន ៣ ចំណុច គឺចំណុចវិវាទទី១, ទី២ និងទី៣។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាតែចំណុចវិវាទដែលនៅសល់ ចំនួន ១ ចំណុច តែប៉ុណ្ណោះ គឺចំណុចវិវាទទី៤។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ និងថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៨ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ។

ភាគីទាំងពីរបានឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៨ ទៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៨ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធិ លេខ ០១១/១៨ ខសស ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៨ របស់ឈ្មោះ ស្តេឡា ឆាង ជានាយកប្រតិបត្តិក្រុមហ៊ុន ខេន ស្ព័ត ស៊ូ គោរពជូន លោកប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំផ្ទេរសិទ្ធិជូនលោក សុះ មើ លោក ឡាច សារុន និងលោក អ៊ុក អ៊ុន ជាតំណាងដោះស្រាយវិវាទការងាររួម ជាមួយក្រុមប្រឹក្សាអាជ្ញាកណ្តាល។

២- ប័ណ្ណពន្ធប៉ាតង់ ក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ PTL ២០១៨០១២៨៨៦ អពដ ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៨។

៣- វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ-សិប្បកម្ម ក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ ៦៨២៣ ឧសកឧ.វប.១២ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧។

៤- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ខេន ស្ព័ត ស៊ូ បានឃើញ និងបញ្ជាក់ថាត្រឹមត្រូវ លេខ ៥១១ ប.ក/ក.ឆ ចុះថ្ងៃទី10 ខែមិថុនា ឆ្នាំ២០១៦ ដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង។

៥- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៨។

៦- សេចក្តីជូនដំណឹង លេខ 00៥/១៨ ខសស ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៨។

៧- កំណត់ហេតុនៃកិច្ចប្រជុំ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ប្រធានបទកិច្ចព្រមព្រៀងប្រើប្រាស់បំណាច់ឆ្នាំរួម សម្រាប់ឆ្នាំ២០១៨។

៨- កិច្ចព្រមព្រៀង លេខ 00៦/១៨ ខសស ចុះថ្ងៃទី0២ ខែកក្កដា ឆ្នាំ២០១៨។

៩- ពាក្យបណ្តឹង ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៨។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតតំណាងដោយអាណត្តិរបស់មេធាវី ហម ស៊ុនរិទ្ធិ គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីតំណាងដោយអាណត្តិ ឱ្យអាណត្តិទាយកឈ្មោះ អេង ស្រីតូច ភេទស្រី ឈ្មោះ រីន សេរី ភេទស្រី និង ឈ្មោះ សៀង នីម ភេទប្រុស ជាតំណាងកម្មករ ក្នុងសំណុំរឿងលេខ ០៣១/១៨ របស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨។

២- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់ឈ្មោះ អេង ស្រីតូច, ឈ្មោះ សៀង នីម និងឈ្មោះ វិន សេរី ប្រគល់សិទ្ធិជូនមេធាវី ហម ស៊ុនរិទ្ធិ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨។

៣- វិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈសហជីពកម្ពុជានៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ ១៣៧៣ កប/កឆ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧។

៤- សារណាការពាររបស់មេធាវី ហម ស៊ុនរិទ្ធិ គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសារណាការពារឱ្យអាណត្តិទាយកឈ្មោះ អេង ស្រីតូច ឈ្មោះ សៀង នីម និង ឈ្មោះ វិន សេរី ដែលអ្នកទាំងអស់គ្នាជាថ្នាក់ដឹកនាំសហជីពកម្ពុជា នៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ មានទីតាំងស្ថិតនៅភូមិចំការស្វាយ ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ រាជធានីភ្នំពេញ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៨។

៥- បញ្ជីឈ្មោះកម្មករនិយោជិតដែលក្រុមហ៊ុនបានអោយឈប់សម្រាកប្រចាំឆ្នាំ ដោយមិនមានការព្រមព្រៀង ពីពួកគាត់។

៦- បញ្ជីឈ្មោះកម្មករ-កម្មការិនី ចូលជាសមាជិក និងយល់ព្រមកាត់ប្រាក់ភាគទាន ជូនសហជីពកម្ពុជានៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ។

៧- លិខិតបញ្ជាក់ការយល់ព្រមឱ្យកាត់ប្រាក់ភាគទានសមាជិកសហជីពកម្ពុជា ពីសាមីកម្មករ។

៨- លិខិតលេខ ០៦៩/១៨ សសក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨ របស់សហព័ន្ធសហជីពកម្ពុជា គោរពជូនលោកនាយកក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ស្តីពីសំណើសុំលោកនាយកជួយកាត់ប្រាក់ភាគទានប្រចាំខែចំពោះសមាជិក សមាជិកា ចំនួន ១០១ នាក់ ជាសមាជិក សមាជិកា សហជីពកម្ពុជានៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ក្នុងម្នាក់ៗ ចំនួន ១០០០ (មួយពាន់) រៀល ចាប់ពីខែមីនា ឆ្នាំ២០១៨ នេះតទៅ។

៩- លិខិតលេខ ១០៧/១៨ សសក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៨ របស់សហព័ន្ធសហជីពកម្ពុជា គោរពជូន លោកនាយកក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ស្តីពីសំណើសុំលោកនាយកជួយកាត់ប្រាក់ភាគទានប្រចាំខែ ចំពោះសមាជិក សមាជិកា ចំនួន ៣៦ នាក់ថ្មី ជាសមាជិក សមាជិកា សហជីពកម្ពុជានៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ក្នុងម្នាក់ៗ ចំនួន ១០០០ (មួយពាន់) រៀល ចាប់ពីខែមេសា ឆ្នាំ២០១៨ នេះតទៅ។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ ១១៤១ កប/កឆ ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៨។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ចុះថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៨។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ លេខ ០០៨/១៨ កប/អក/វក/លបវ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៨ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង។

THE ARBITRATION COUNCIL

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ២១៣ កប/អក/វក/លកអ. ចុះថ្ងៃអង្គារ ១០កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ២១៤ កប/អក/វក/លកអ. ចុះថ្ងៃអង្គារ ១០កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៨។

**អនុហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

**ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖**

- ក្រុមហ៊ុន ខេន ស្ព័ត ស៊ូ គឺជាក្រុមហ៊ុនដែលមានសកម្មភាពចម្បងក្នុងការផលិតស្បែកជើង និងបានទទួលវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ-សិប្បកម្ម(ឆ្នាំទី៧) ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧ របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ បច្ចុប្បន្នក្រុមហ៊ុននេះ ជួលកម្មករនិយោជិតចំនួនប្រហែលជា ៧៣០៣ នាក់ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ)*
- សហជីពកម្ពុជា នៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ទទួលបានវិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ ពីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង ក្រោមលេខចុះបញ្ជី ១០៤១៧០០២៥ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧។
- នៅក្នុងសំណុំរឿងនេះ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម លេខ ០០៨/១៨ កប/កឆ/លបវ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៨ ដែលមានកម្មករនិយោជិត ចំនួន ៣ នាក់ គឺ ១. លោកស្រី អៀង ស្រីទូច ២. លោកស្រី វីន សេរី និង៣. លោក សៀង នីម ជាតំណាងភាគីកម្មករនិយោជិតនៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ក្នុងការដោះស្រាយវិវាទការងាររួម។
- យោងតាមលិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិ ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៨ របស់ភាគីកម្មករនិយោជិត ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា កម្មករនិយោជិតទាំង ៣ នាក់ ដែលមានឈ្មោះនៅក្នុងលិខិតបញ្ជាក់អ្នកតំណាងដែលចេញដោយមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង ខាងលើ បានផ្ទេរសិទ្ធិជូនលោកមេធាវី ហាម ស៊ុនរិទ្ធិ ឱ្យធ្វើជាអ្នកតំណាងដោយអាណត្តិរបស់ពួកគាត់ ដើម្បីដោះស្រាយវិវាទនៅក្នុងនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល។

THE ARBITRATION COUNCIL

- នៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺមានវត្តមានកម្មករនិយោជិត ចំនួន ៣ នាក់ ដែលមានឈ្មោះនៅក្នុងលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិត ជាមួយនឹងវត្តមានរបស់លោកមេធាវី ហាម ស៊ុនរិទ្ធិ ព្រមទាំងកម្មករនិយោជិត ចំនួន ៦នាក់ ផ្សេងទៀត។
- នៅក្នុងសំណុំរឿងនេះ ភាគីទាំងពីរបានទទួលស្គាល់ថា នៅក្នុងក្រុមហ៊ុនមិនទាន់មានសហជីពដែលមានភាពជាតំណាងបំផុតទេ។

**ចំណុចវិវាទទី ៤ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកកាត់ប្រាក់ភាគទានជូនសហជីពកម្ពុជា ដែលបានដាក់ជូនក្រុមហ៊ុនកន្លងមក**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារថា ឱ្យនិយោជកកាត់ប្រាក់ឈ្នួលកម្មករនិយោជិតដែលជាសមាជិកសហជីពកម្ពុជា ក្នុងម្នាក់ ១០០០ រៀល ដើម្បីបង់ភាគទានជូនសហជីពកម្ពុជា ចាប់ខែកញ្ញា ឆ្នាំ២០១៨ នេះតទៅ។
- ភាគីទាំងពីរទទួលស្គាល់ថា ការអនុវត្តសព្វថ្ងៃនៅក្នុងក្រុមហ៊ុន គឺ ៖
  - o និយោជកឱ្យកម្មករនិយោជិតម្នាក់ៗ ដែលយល់ព្រមឱ្យនិយោជកកាត់ប្រាក់ឈ្នួលដើម្បីបង់ភាគទានជូនសហជីពដែលគាត់ជាសមាជិក យកលិខិតស្នើសុំកាត់ភាគទានសហជីពរបស់គាត់ ទៅដាក់នៅផ្នែករដ្ឋបាលដោយខ្លួនឯងផ្ទាល់ ទើបនិយោជកកាត់ប្រាក់ឈ្នួលដើម្បីបង់ភាគទានសហជីព។
  - o បើទោះបីជាតំណាងសហជីពកម្ពុជា ដាក់លិខិតស្នើសុំកាត់ភាគទានសហជីពដោយមានភ្ជាប់ជាមួយលិខិតយល់ព្រមកាត់ប្រាក់ឈ្នួលពីកម្មករនិយោជិតក៏ដោយ ប៉ុន្តែ បើមិនមានវត្តមានកម្មករនិយោជិតមកស្នើសុំដោយផ្ទាល់ និយោជកមិនព្រមកាត់តាមការស្នើសុំនោះទេ។ សហជីពកម្ពុជា នៃក្រុមហ៊ុន ខេន ស៊័ត ស៊ូ បានដាក់លិខិតស្នើសុំទៅនិយោជកនៅខែមេសា ឆ្នាំ២០១៨ ដោយមានភ្ជាប់ជាមួយនឹងលិខិតយល់ព្រមរបស់កម្មករនិយោជិតដែលមានឈ្មោះ និងស្នាមមេដៃ ឱ្យកាត់ប្រាក់ឈ្នួល ប៉ុន្តែនិយោជកមិនព្រមទទួលយក និងមិនកាត់ប្រាក់ឈ្នួលជូនសហជីពកម្ពុជានោះទេ។
  - o និយោជកបានអនុញ្ញាតឱ្យកម្មករនិយោជិតម្នាក់ៗ យកលិខិតស្នើសុំកាត់ប្រាក់ឈ្នួលបង់ភាគទានសហជីព មកផ្នែករដ្ឋបាលនៅរៀងរាល់ថ្ងៃធ្វើការ វេលាម៉ោង ១១ និង ៣០ នាទី ព្រឹក រហូតដល់ម៉ោង ១២ និង ៣០ នាទី ថ្ងៃត្រង់ ដែលជាម៉ោងសម្រាកបាយថ្ងៃត្រង់។
- ភាគីកម្មករនិយោជិតបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - o និយោជកមានកាតព្វកិច្ចកាត់ប្រាក់ឈ្នួលកម្មករនិយោជិតដើម្បីបង់ភាគទានសហជីព តាមការយល់ព្រមរបស់កម្មករនិយោជិត។
  - o កាលពីមុននិយោជកមិនបានតម្រូវឱ្យកម្មករនិយោជិតយកលិខិតយល់ព្រមកាត់ប្រាក់ឈ្នួលបង់ភាគទានសហជីពទៅនិយោជកផ្ទាល់នោះទេ គឺសហជីពអាចដាក់លិខិតនោះទៅនិយោជកបាន។ ទើបតែបច្ចុប្បន្ននេះ និយោជកបានផ្លាស់ប្តូរការអនុវត្តនេះចំពោះសហជីពកម្ពុជា ដោយឱ្យកម្មករនិយោជិតយកលិខិតយល់ព្រមកាត់ប្រាក់ឈ្នួលនោះទៅផ្ទាល់ ទើបនិយោជកកាត់ជូន។

o មិនមានច្បាប់ណាចែងថាសហជីពមិនមានសិទ្ធិដាក់លិខិតស្នើសុំកាត់ភាគទានសហជីពនោះទេ ម្យ៉ាងទៀត សហជីពក៏បានភ្ជាប់ជាមួយលិខិតយល់ព្រមពីកម្មករនិយោជិត ដើម្បីកាត់ប្រាក់ឈ្នួលនេះដែរ។

o កម្មករនិយោជិតម្នាក់ៗ មិនបានចូលជួបរដ្ឋបាលនោះទេ ដោយសារគាត់ខ្លាចរដ្ឋបាល ព្រោះមានករណីខ្លះ រដ្ឋបាលបានសួរនាំគាត់ទាក់ទងនឹងការចូលរួមជាសមាជិកសហជីព ហើយពេលខ្លះទៀតនិយោជកបានបញ្ចុះបញ្ចូលកម្មករនិយោជិតមិនឱ្យចូលជាសមាជិកសហជីព។

- ភាគីនិយោជកបានបញ្ជាក់ថា និយោជកនឹងកាត់ប្រាក់ភាគទានជូនសហជីពនៅពេលដែលកម្មករនិយោជិតម្នាក់ៗ ដែលជាសមាជិកសហជីពនោះ យកលិខិតយល់ព្រមឱ្យកាត់ប្រាក់ឈ្នួលនោះ ទៅជូនផ្នែករដ្ឋបាលដោយខ្លួនគាត់ផ្ទាល់ ឬជាមួយតំណាងសហជីពរបស់គាត់។ ដោយមូលហេតុថា ការអនុវត្តពីមុនធ្លាប់មានបញ្ហា មានកម្មករនិយោជិតមួយចំនួនបានតវ៉ាថា ពួកគាត់មិនបានយល់ព្រមឱ្យនិយោជកកាត់ប្រាក់ឈ្នួលបង់ភាគទានសហជីព ហេតុនេះ ទើបនិយោជកផ្លាស់ប្តូរការអនុវត្ត ដោយឱ្យកម្មករនិយោជិតមកដោយខ្លួនឯងផ្ទាល់វិញ។

- យោងតាមសារណារបស់ភាគីកម្មករនិយោជិតពាក់ព័ន្ធនឹងចំណុចនេះ ភាគីកម្មករនិយោជិតបានបញ្ជាក់ថា កម្មករនិយោជិតដែលយល់ព្រមឱ្យនិយោជកកាត់ប្រាក់ឈ្នួលដើម្បីបង់ភាគទានសហជីពកម្ពុជា គឺមានកម្មករនិយោជិត ចំនួន ១៦៧ នាក់។ ដោយឡែក យោងតាមលិខិតបញ្ជាក់ការយល់ព្រមឱ្យកាត់ប្រាក់ភាគទានសហជីពកម្ពុជា ដែលមានឈ្មោះ និងស្នាមមេដៃ ឬហត្ថលេខារបស់កម្មករនិយោជិតម្នាក់ៗ ដែលភាគីកម្មករនិយោជិតដាក់ជូនក្រុមប្រឹក្សាអាជ្ញាកណ្តាលដើម្បីពិនិត្យ និងពិចារណា ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញមានកម្មករនិយោជិតសរុប ចំនួន ១៥៤ នាក់ ប៉ុណ្ណោះ។

## ហេតុផលនៃសេចក្តីសម្រេច ៖

មុននឹងពិចារណាចំណុចទាមទារខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងបកស្រាយអំពីភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ ដូចខាងក្រោម ៖

កថាខណ្ឌទី១ នៃមាត្រា ៥៤ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ចែងថា ៖ "*ភាពជាតំណាងបំផុតនៃសហជីពត្រូវបានទទួលស្គាល់នៅក្នុងក្របខ័ណ្ឌនៃសហគ្រាស ឬគ្រឹះស្ថាន។ សម្រាប់គោលបំណងនៃការចរចាអនុសញ្ញារួម ឬដោះស្រាយវិវាទការងាររួម គឺសហជីពដែលមានភាពជាតំណាងបំផុតទទួលបានសិទ្ធិផ្តាច់មុខ។*"។

យោងតាមកថាខណ្ឌទី១ នៃមាត្រា ៥៤ នៃច្បាប់ស្តីពីសហជីពខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា មានតែសហជីពដែលមានភាពជាតំណាងបំផុតប៉ុណ្ណោះ ដែលមានសិទ្ធិផ្តាច់មុខនៅក្នុងការចរចាឬផ្តើតអនុសញ្ញារួម និងដោះស្រាយវិវាទការងាររួម។ សិទ្ធិផ្តាច់មុខក្នុងការដោះស្រាយវិវាទការងាររួមនេះ សំដៅលើសិទ្ធិក្នុងការនាំយកវិវាទ និងធ្វើជាតំណាងឱ្យកម្មករនិយោជិតនៅគ្រប់នីតិវិធីដោះស្រាយវិវាទការងាររួម ដោយរួមបញ្ចូលទាំងនីតិវិធីដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ១៧៦/១៦-*

*ដេវើលិន ខូអិលធីឌី, លេខ ១៨៣/១៦-យីដា មេនូហ្វេកឆឺរី ខូអិលធីឌី, លេខ ១៨៤/១៦-ឃ្វីនធ៍ មេជើរ អ៊ីនដាស ស្ទ្រៀល ខូអិលធីឌី, លេខ ១៨៨/១៦-ហ្គ្រីនសាំមីត (ខេមបូឌា) លីមីធីត, លេខ ២២៧/១៦-អេវើរី ថេកស្តាយ ហ្គាមេន (ខេមបូឌា) ខូអិលធីឌី និង លេខ ០០១/១៧-ដាយអ៊ីម៉ិន ស៊ីធី ប្រាយវេត លីមីធីត ខមភេនី)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ ក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

នៅក្នុងសំណុំរឿងនេះ នៅក្នុងក្រុមហ៊ុន ខេន ស្ព័ត ស៊ូ មិនទាន់មានសហជីពដែលមានភាពជាតំណាងបំផុត នោះទេ។

ប្រការ ១៦ នៃប្រកាសលេខ ៣០៣ ក.ប/ប្រ.ក.គ.ប.ក ស្តីពីភាពជាតំណាងបំផុតនៃសហជីព និងបែបបទ និងនីតិវិធីដើម្បីទទួលបានភាពជាតំណាងបំផុត ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨ ចែងថា ៖ *"ក្នុងករណីសហគ្រាស គ្រឹះស្ថានដែលពុំទាន់មានសហជីព ឬពុំទាន់មានសហជីពដែលមានភាពជាតំណាងបំផុត ការដោះស្រាយវិវាទការងាររួម ត្រូវដោះស្រាយដោយអ្នកតំណាងកម្មករនិយោជិត ។"* ។

លើសពីនេះទៀត ប្រការ ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ស្តីពីការធ្វើប្រតិភូកម្មមុខងារក្នុងការធ្វើ បណ្តឹងអំពីវិវាទការងាររួម និងចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចែងថា ៖ *"ត្រូវបានធ្វើប្រតិភូកម្មជូនដល់ប្រធាននាយកដ្ឋានវិវាទការ ងារ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត នូវមុខងារ ដូចខាងក្រោម ៖*

*...*

*- ចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា សម្រាប់ដោះស្រាយវិវាទការងាររួម ។"*។

យោងតាមប្រការ ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា នាយកដ្ឋានវិវាទការងារ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មានមុខងារក្នុងការទទួលស្គាល់ កម្មករនិយោជិត ឱ្យធ្វើជាតំណាងរបស់ភាគីកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទការងាររួម។ ដូច្នេះ កម្មករ និយោជិតដែលត្រូវបានទទួលស្គាល់ដោយនាយកដ្ឋានវិវាទការងារ ឬប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្ត មានសិទ្ធិស្របច្បាប់ក្នុងការតំណាងឱ្យភាគីកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទការងាររួម ដោយរួមទាំងនៅ ដំណាក់កាលដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ។ នៅពេលមិនទាន់មានវត្តមានរបស់ សហជីពមានភាពតំណាងបំផុត។ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ២២៣/១៦-យូនីកគា ថេកណឡជី (ខេមបូឌា), លេខ ២២៤/១៦-កាស៊ីណូកោះមាស និងសណ្ឋាគារ, លេខ ២៣៧/១៦-ហ៊្សិណា-ដាយដុង (ខេមបូឌា) អេឡិចត្រូនិច និង លេខ ០០៨/១៧-ថបវើលដ៏ ហ្គាមិន (ខេមបូឌា) អិលធីឌី)*

នៅក្នុងសំណុំរឿងនេះ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង បានចេញលិខិតបញ្ជាក់ អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម លេខ ០០៨/១៨ កឆ្ន/គរ/ចេបា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១៨ ដែលមានកម្មករនិយោជិត ចំនួន ៣ នាក់ គឺ ១. លោកស្រី អៀង ស៊ីទូ ២. លោកស្រី ទៃ សេរី និង៣. លោក សៀង នីម ជាតំណាងភាគីកម្មករនិយោជិតនៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ក្នុងការដោះស្រាយ

វិវាទការងាររួម។ នៅថ្ងៃសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល គឺមានវត្តមានកម្មករនិយោជិត ចំនួន ៣ នាក់ ដែលមានឈ្មោះនៅក្នុងលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតខាងលើ ព្រមទាំងមានវត្តមានរបស់កម្មករនិយោជិតមួយចំនួនផ្សេងទៀតផងដែរ។

ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតទាំង ៣ នាក់ ខាងលើ មានសិទ្ធិតំណាងកម្មករនិយោជិតនៃក្រុមហ៊ុន ខេន ស៊្កត ស៊ូ ក្នុងការដោះស្រាយវិវាទការងាររួមនៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលដោះស្រាយចំណុចវិវាទទាំងនេះ សម្រាប់កម្មករនិយោជិតនៃក្រុមហ៊ុន ខេន ស៊្កត ស៊ូ ដែលជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ។

**ចំណុចវិវាទទី ៤ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកកាត់ប្រាក់ឈ្នួលកម្មករនិយោជិត ដែលជាសមាជិកសហជីពកម្ពុជា ក្នុងម្នាក់ ១០០០ រៀល ដើម្បីបង់ភាគទានជូនសហជីពកម្ពុជា ចាប់ពីខែកញ្ញា ឆ្នាំ២០១៨ នេះតទៅ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចក្នុងការកាត់ប្រាក់ឈ្នួលកម្មករនិយោជិត ដែលជាសមាជិកសហជីពកម្ពុជា ក្នុងម្នាក់ ១០០០ រៀល ដើម្បីបង់ភាគទានជូនសហជីពកម្ពុជា ចាប់ពីខែកញ្ញា ឆ្នាំ២០១៨ ដែរ ឬទេ?

មាត្រា ១២៩ នៃច្បាប់ស្តីពីការងារ ចែងថា ៖ *"អនុសញ្ញារួមដែលអនុញ្ញាតឱ្យដកហូតលើប្រាក់ឈ្នួល ក្រៅពីករណីទាំងនេះ ត្រូវទុកដោយមោឃៈដោយពេញច្បាប់។*

*ប៉ុន្តែ កម្មករនិយោជិតអាចអនុញ្ញាតឱ្យកាត់ប្រាក់ឈ្នួលរបស់ខ្លួន ដើម្បីបង់ភាគទានសហជីព ដែលខ្លួនជាសមាជិក។ ការអនុញ្ញាតនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងអាចបដិសេធវិញបានគ្រប់ពេលវេលា។"*

កថាខណ្ឌទី១ មាត្រា ២៦ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ចែងថា ៖ *"និយោជកត្រូវកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិត ដែលជាសមាជិកសហជីព ដើម្បីផ្ទេរទៅឱ្យសហជីពនោះជាស្វ័យប្រវត្តិ ក្រោយពីមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីកម្មករ និយោជិត។ បែបបទអនុវត្តត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។"*

យោងតាមមាត្រា ១២៩ នៃច្បាប់ស្តីពីការងារ និងមាត្រា ២៦ នៃច្បាប់ស្តីពីសហជីពខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតអាចអនុញ្ញាតឱ្យនិយោជកកាត់ប្រាក់ឈ្នួលរបស់ខ្លួន ដើម្បីបង់ភាគទានសហជីព។ ការអនុញ្ញាតនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ នៅពេលដែលកម្មករនិយោជិតយល់ព្រមឱ្យនិយោជកកាត់ប្រាក់ឈ្នួលដើម្បីបង់ភាគទានសហជីពដែលខ្លួនជាសមាជិក។ ហេតុនេះ និយោជកមានកាតព្វកិច្ចកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតដែលបានយល់ព្រមជាលាយលក្ខណ៍អក្សរ ដើម្បីបង់ភាគទានសហជីពដែលកម្មករនិយោជិតនោះជាសមាជិក ទៅឱ្យសហជីពនោះជាស្វ័យប្រវត្តិ។ ចំពោះនីតិវិធី និងបែបបទនៃការកាត់ប្រាក់ភាគទាននេះ គឺត្រូវអនុវត្តតាមប្រកាសរបស់ក្រសួងទទួលបន្ទុកវិស័យការងារ។

THE ARBITRATION COUNCIL

យោងតាមប្រការ ១ នៃប្រកាសលេខ ៣០០ ក.ប/ប្រ.ក.គ.ប.ក ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨ ស្តីពីនីតិវិធីនៃការបង់ប្រាក់ភាគទានសហជីព និងប្រាក់សេវាភ្នាក់ងារ បានចែងថា ៖ *"សហជីពអាចស្នើសុំឱ្យនិយោជកកាត់ប្រាក់ភាគទានពីសមាជិករបស់ខ្លួនបាន លុះត្រាតែសហជីពនោះបានចុះបញ្ជីត្រឹមត្រូវស្របតាមច្បាប់ស្តីពីសហជីព ។"*

ករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា សហជីពកម្ពុជា នៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ ទទួលបានវិញ្ញាបនបត្រចុះបញ្ជីអង្គការវិជ្ជាជីវៈ ពីមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង ក្រោមលេខចុះបញ្ជី ១០៤១៧០០២៥ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១៧។ ហេតុនេះ សហជីពកម្ពុជា នៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ មានសិទ្ធិស្នើសុំឱ្យនិយោជកកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតដែលជាសមាជិកសហជីពសម្រាប់បង់ភាគទានសហជីពបាន។

ទន្ទឹមនឹងនេះ កថាខណ្ឌទី២ ប្រការ ៤ នៃប្រកាសលេខ ៣០០ ក.ប/ប្រ.ក.ក.ប.ក ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨ ដដែល ខាងលើ បានចែងថា ៖ *"សហជីពត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់និយោជក ឱ្យបានយ៉ាងតិច ១០(ដប់)ថ្ងៃ មុនការចាប់ផ្តើមកាត់ប្រាក់ឈ្នួលសម្រាប់បង់ភាគទានសហជីព អំពីចំនួនប្រាក់ភាគទានសហជីពដែលនឹងត្រូវកាត់ពីប្រាក់ឈ្នួលរបស់កម្មករនិយោជិតដែលជាសមាជិករបស់ខ្លួន ។ សហជីពត្រូវភ្ជាប់មកជាមួយនូវលិខិតយល់ព្រមឱ្យកាត់ប្រាក់ឈ្នួលសម្រាប់បង់ភាគទានសហជីព ដែលមានចុះកាលបរិច្ឆេទនិងហត្ថលេខា ឬស្នាមម្រាមដៃរបស់កម្មករនិយោជិតសាមី ។"*

យោងតាមកថាខណ្ឌទី២ ប្រការ ៤ នៃប្រកាសលេខ ៣០០ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សហជីពត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់និយោជកឱ្យបានយ៉ាងតិច ១០ ថ្ងៃ មុនពេលចាប់ផ្តើមកាត់ប្រាក់ឈ្នួលរបស់កម្មករនិយោជិតសម្រាប់បង់ភាគទានសហជីព អំពីចំនួនប្រាក់ភាគទានដែលត្រូវកាត់ និងត្រូវមានភ្ជាប់មកជាមួយនឹងលិខិតយល់ព្រមឱ្យកាត់ប្រាក់ឈ្នួលសម្រាប់បង់ភាគទានសហជីពដែលមានចុះកាលបរិច្ឆេទ និងហត្ថលេខា ឬស្នាមម្រាមដៃរបស់កម្មករនិយោជិត។

យោងតាមអង្គហេតុ នៅខែមេសា ឆ្នាំ២០១៨ សហជីពកម្ពុជា នៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ បានដាក់លិខិតស្នើសុំទៅនិយោជកឱ្យកាត់ប្រាក់ឈ្នួលដើម្បីបង់ភាគទានចូលសហជីព ដោយមានភ្ជាប់ជាមួយនឹងលិខិតយល់ព្រមរបស់កម្មករនិយោជិតដែលមានឈ្មោះ និងស្នាមមេដៃរបស់ពួកគាត់។ ដោយឡែក ផ្នែករដ្ឋបាលមិនព្រមទទួលយក និងមិនកាត់ប្រាក់ឈ្នួលជូនសហជីពកម្ពុជានោះទេ ដោយមូលហេតុថា កម្មករនិយោជិតមិនបានយកលិខិតយល់ព្រមរបស់ពួកគាត់ឱ្យនិយោជកកាត់ប្រាក់ឈ្នួលបង់ភាគទានសហជីព មកដាក់នៅផ្នែករដ្ឋបាលដោយផ្ទាល់ ហេតុនេះ និយោជកមិនកាត់ប្រាក់ឈ្នួលបង់ភាគទានជូនសហជីពទេ។

យោងតាមការបកស្រាយពាក់ព័ន្ធនឹងប្រការ១ និងកថាខណ្ឌទី២ ប្រការ ៤ នៃប្រកាសលេខ ៣០០ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា សហជីពកម្ពុជាគឺជាសហជីពដែលមានបញ្ជិកាត្រឹមត្រូវ ហើយសហជីពនេះមានសិទ្ធិដាក់លិខិតស្នើសុំឱ្យនិយោជកកាត់ប្រាក់ឈ្នួលពីសមាជិករបស់ខ្លួនបាន ដោយសហជីពត្រូវតែភ្ជាប់ជាមួយនឹងលិខិតយល់ព្រមរបស់កម្មករនិយោជិត ដែលមានកាលបរិច្ឆេទច្បាស់លាស់ និងស្នាមមេដៃ ឬហត្ថលេខារបស់កម្មករនិយោជិតផ្ទាល់។ លើសពីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា មិនមានច្បាប់ ឬបទដ្ឋានគតិយុត្តណាមួយដែលតម្រូវឱ្យកម្មករនិយោជិតដែលមានបំណងឱ្យនិយោជកកាត់ប្រាក់ឈ្នួលរបស់ខ្លួនសម្រាប់បង់ភាគទានសហជីព

មកដាក់ការស្នើសុំដោយផ្ទាល់ទៅនិយោជកនោះទេ។ សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ការអនុវត្តរបស់និយោជក ដែលតម្រូវឱ្យកម្មករនិយោជិតមកដាក់លិខិតយល់ព្រមកាត់ប្រាក់ឈ្នួលសម្រាប់បង់ភាគទានសហជីពដោយផ្ទាល់ជាមួយផ្នែករដ្ឋបាល ទើបនិយោជកព្រមកាត់ប្រាក់ឈ្នួលសម្រាប់បង់ភាគទានសហជីព គឺជាការអនុវត្តដែលមិនត្រឹមត្រូវស្របតាមប្រកាសលេខ ៣០០ ខាងលើនេះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមានកាតព្វកិច្ចក្នុងការកាត់ប្រាក់ឈ្នួលកម្មករនិយោជិតដែលជាសមាជិករបស់សហជីពកម្ពុជានៃក្រុមហ៊ុន ខេន ស្ព័ត ស៊ូ តាមការស្នើសុំរបស់សហជីព។

សរុបសេចក្តីមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បង្គាប់ឱ្យនិយោជកកាត់ប្រាក់ឈ្នួលកម្មករនិយោជិតដែលជាសមាជិករបស់សហជីពកម្ពុជា ក្នុងម្នាក់ ចំនួន ១០០០ រៀល ក្នុងមួយខែ ជូនសហជីពកម្ពុជា នៅពេលដែលសហជីពកម្ពុជាដាក់លិខិតស្នើសុំកាត់ប្រាក់ភាគទាន និងមានភ្ជាប់មកជាមួយនឹងលិខិតយល់ព្រមរបស់កម្មករនិយោជិតដែលមានចុះកាលបរិច្ឆេទ ហត្ថលេខា ឬស្នាមម្រាមដៃ។

យោងតាមអង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទទី ៤៖**

- បង្គាប់ឱ្យនិយោជកកាត់ប្រាក់ឈ្នួលកម្មករនិយោជិតដែលជាសមាជិករបស់សហជីពកម្ពុជា ក្នុងម្នាក់ ចំនួន ១០០០ រៀល ក្នុងមួយខែ ជូនសហជីពកម្ពុជា នៅពេលដែលសហជីពកម្ពុជាដាក់លិខិតស្នើសុំកាត់ប្រាក់ភាគទាន និងមានភ្ជាប់មកជាមួយនឹងលិខិតយល់ព្រមរបស់កម្មករនិយោជិត ដែលមានចុះកាលបរិច្ឆេទ ហត្ថលេខា ឬស្នាមម្រាមដៃ។

**ប្រភេទនៃសេចក្តីបង្គាប់៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

*សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងរយៈពេលនេះទេ។*

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក៖**

ឈ្មោះ៖ **អ៊ិន សុនី**

ហត្ថលេខា៖ ----------------------------

**អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត៖**

ឈ្មោះ៖ **លីវ សុវណ្ណា**

ហត្ថលេខា៖----------------------------

THE ARBITRATION COUNCIL

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ប៉ែន ប៊ុនឈា**

ហត្ថលេខា ៖ ----------------------------------------